# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

No. 36 PR-17/EoJ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧

## មហោស្រពភាពយន្តជប៉ុនប្រចាំឆ្នាំ២០១៧

មូលនិធិជប៉ុន និងស្ថានទូតជប៉ុន រួមសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន នឹងរៀបចំមហោស្រពភាពយន្តជប៉ុន២០១៧នៅកម្ពុជា ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅរោងភាពយន្ត Major Cineplex (AEON Mall) និងរោងភាពយន្ត Legendទួកគោក នៅទីក្រុងភ្នំពេញ។

មានភាពយន្តជាច្រើនប្រភេទដែលត្រូវបានសម្រិតសម្រាំង សម្រាប់ការដាក់បញ្ចាំងនៅរោងភាពយន្តធំៗនៅទីក្រុងភ្នំពេញដូចដែលបានជម្រាបជូនខាងលើ។ ភាពយន្តទាំងនោះរួមមានភាពយន្តគំនូរជីវចល ភាពយន្តបែបមនោសញ្ចេតនា ភាពយន្តឯកសារ ហើយក្នុងនោះមានខ្សែភាពយន្តខ្លះធ្លាប់ទទួលបានពានរង្វាន់ផងដែរ។ ភាពយន្តដែលនឹងត្រូវចាក់បញ្ចាំងនេះ ឆ្លុះបញ្ចាំងអំពីជីវភាពរស់នៅរបស់ប្រជាជនជប៉ុន សង្គម និងវប្បធម៌ជប៉ុន ហើយមហោស្រពនេះក៏ផ្តល់ឱកាសដ៏ល្អមួយសម្រាប់អ្នកទស្សនាដើម្បីអាចស្គាល់អំពីប្រទេស និងប្រជាជនជប៉ុន។

សម្រាប់ឆ្នាំនេះភាពយន្តជប៉ុនចំនួន១២រឿងនឹងត្រូវបានចាក់បញ្ចាំងជាមួយចំណងជើងរងជាភាសាខ្មែរ និងភាសាអង់គ្លេស។ សម្រាប់កម្មវិធីលម្អិតនៃការចាក់បញ្ចាំងមានផ្សព្វផ្សាយនៅលើគេហទំព័រនៃមហោស្រពភាពយន្តជប៉ុនដូចខាងក្រោម៖
http://kh.japanesefilmfest.org/screening-schedule/

មហោស្រពភាពយន្តជប៉ុន ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០១៥មក ក្នុងគោលបំណងជំរុញការយល់ដឹងអំពីជីវភាពរស់នៅរបស់ប្រជាជននិងវប្បធម៌ជប៉ុនដល់ប្រជាជនកម្ពុជា តាមរយៈការចាក់បញ្ចាំងភាពយន្ត។

ការចូលរួមដោយសេរី។ ចំពោះព័ត៌មានលម្អិតអំពីកាលបរិច្ឆេទ និងពេលវេលានៃការចាក់បញ្ចាំង សូមចូលទៅកាន់កម្មវិធីដូចដែលមានភ្ជាប់។

ចំពោះសំណួរផ្សេងៗ សូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈលេខទូរស័ព្ទ ០២៣ ២១៧ ១៦១ រឺក៏ផ្ញើអ៊ីម៉េលមកកាន់អាស័យដ្ឋានដូចខាងក្រោម៖
info.jpn@pp.mofa.go.jp ។